

# មើមឆៃថាវដ៏ធំ

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

សូមស្កេនQR Code

គំនូរជីវចល ធនធានបង្រៀន

និពន្ធនិងរូបភាពដោយ និស្សិតនៅប្រទេសជប៉ុន



កាលពីព្រេងនាយ មានលោកតាម្នាក់បានដាំដំណាំផ្លែថាវ។

គាត់ក៏បាននិយាយ « កូនផ្លែថាវអើយកូនផ្លែថាវ ឯងត្រូវតែឆាប់ធំឡើង មានមើមធំនិងមានរសជាតិឆ្ងាញ់ »។



កូនឆៃថាវបានលូតលាស់ស្លឹកខៀវស្រងាត់ មើលទៅមានរសជាតិឆ្ងាញ់ ហើយមើមវាពិតជាធំខ្លាំងណាស់។



នៅថ្ងៃមួយ លោកតាក៏បានទៅដកមើមឆៃថាវនោះ។
លោកតាបានខំប្រឹងទាញមើមឆៃថាវនោះម្តងហើយម្តងទៀត នៅតែទាញមិនរួច។



លោកតាក៏បានទៅហៅលោកយាយឱ្យមកជួយ។ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។
ពួកគេបានខំប្រឹងទាញមើមឆៃថាវនោះម្តងហើយម្តងទៀត ប៉ុន្តែនៅតែទាញមិនរួច។



ដូច្នេះលោកយាយក៏បានទៅហៅចៅស្រីរបស់គាត់ឱ្យមកជួយ។
ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា ហើយលោកតាទាញមើមឆៃថាវ។
ពួកគេបានទាញមើមឆៃថាវនោះម្តងហើយម្តងទៀត នៅតែមិនរួច។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ចៅស្រីបានទៅហៅកូនក្របីឱ្យមកជួយ។
កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។
ពួកគេបានទាញមើមឆៃថាវនោះម្តងហើយម្តងទៀត ប៉ុន្តែនៅតែមិនរួច។



កូនក្របីក៏បានទៅហៅកូនស្វាឱ្យមកជួយ។ កូនស្វាទាញកូនក្របី កូនក្របីទាញចៅស្រី
ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។
ពួកគេបានខំប្រឹងទាញឆៃថាវនោះម្ដងហើយម្ដងទៀត ប៉ុន្តែនៅតែមិនរួច។



កូនស្វាបានទៅហៅអណ្តើកឱ្យមកជួយ។ អណ្តើកទាញកូនស្វា កូនស្វាទាញកូនក្របី កូនក្របីទាញចៅស្រី ចៅស្រីទាញលោកយាយ លោកយាយទាញលោកតា លោកតាទាញមើមឆៃថាវ។

ពួកគេបានខំប្រឹងទាញមើមឆៃថាវនោះម្តងហើយម្តងទៀត...



...ចុងក្រោយ ពួកគេពិតជាធ្វើបានសម្រេចមែន។ ពួកគេដកមើមឆៃថាវនោះបានហើយ!